ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៣៤ សសរ.

# សេចក្តីសម្រេច
# ស្តីពី
# ការប្រគល់សិទ្ធិចុះហត្ថលេខានៅក្នុង
# គណៈកម្មាធិការប្រតិបត្តិ នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៣/នស/៩៤ ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា និង ព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៩ ចុះថ្ងៃទី ២៤ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១១១ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០០៥ ស្តីពីការអនុវត្តច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ១១ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពីការបង្កើតប្រព័ន្ធជាតិសម្រាប់គ្រប់គ្រងវិនិយោគសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤៨៦ អនក្រ.បក. ចុះថ្ងៃទី១៤ ខែ តុលា ឆ្នាំ ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- បានឃើញសេចក្តីសម្រេចលេខ ២៨ សសរ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០១៣ ស្តីពីការកំណត់របៀបរបបការងារ និងការបែងចែកភារកិច្ចរបស់ថ្នាក់ដឹកនាំរាជរដ្ឋាភិបាល
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ១.-**

ប្រគល់សិទ្ធិចុះហត្ថលេខានៅក្នុងគណៈកម្មាធិការប្រតិបត្តិនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាមានដូចតទៅ :

**ក.** ឯកឧត្តម **គាត ឈន់** អនុប្រធានទី១ : មានសិទ្ធិចុះហត្ថលេខាលើលិខិតទាំងឡាយដែលមានកិរិតនយោបាយ និងលិខិត ឬ ឯកសារដូចមានខាងក្រោម :

- លិខិតសុំយោបល់សម្រេចពីប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឬ ពីរាជរដ្ឋាភិបាលក្នុងការលើក និងស្នើគោលនយោបាយយុទ្ធសាស្ត្រពាណិជ្ជកម្ម ឧស្សាហកម្ម និងវិនិយោគឯកជន
- លិខិតជូនប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សុំពិនិត្យ និងសម្រេចលើគំរោងវិនិយោគឯកជនដែលមានវេយិភាពខ្ពស់
- លិខិតទំនាក់ទំនងជាមួយប្រធាន ឬ តំណាងជាន់ខ្ពស់នៃស្ថាប័នហិរញ្ញប្បទានសហប្រតិបត្តិការ
- លិខិតទំនាក់ទំនងជាមួយប្រធានស្ថាប័នរដ្ឋ និងអភិបាលនៃគណៈអភិបាលរាជធានី-ខេត្តដែលពាក់ព័ន្ធការងារគោលនយោបាយយុទ្ធសាស្ត្រពាណិជ្ជកម្ម ឧស្សាហកម្ម និងវិនិយោគឯកជន និងការងារគណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា
- ប្រកាសតែងតាំងតួនាទីរបស់មន្ត្រីរាជការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាពីថ្នាក់អនុប្រធាននាយកដ្ឋានចុះក្រោម

២. ឯកឧត្តម **ស៊ុន ចាន់ថុល** អនុប្រធាន : មានសិទ្ធិចុះហត្ថលេខាលើលិខិត ឬ ឯកសារដូចមានខាងក្រោម :

- លិខិតទំនាក់ទំនងជាមួយប្រធានស្ថាប័នរដ្ឋ និងអភិបាលនៃគណៈអភិបាលរាជធានី-ខេត្ត ដែលពាក់ព័ន្ធនឹងកិច្ចការរបស់គណៈកម្មាធិការវិនិយោគកម្ពុជា
- លិខិតជូនអនុប្រធានទី១ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សុំពិនិត្យ និងសម្រេចលើគម្រោងវិនិយោគឯកជន
- លិខិតទំនាក់ទំនងជាមួយប្រធាន ឬ តំណាងជាន់ខ្ពស់ក្នុងក្របខ័ណ្ឌអាស៊ាន ។

**ប្រការ២ .-**

អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មានសិទ្ធិចុះហត្ថលេខាលើលិខិត និងឯកសារដូចមានខាងក្រោម :

- លិខិតដកប្រាក់កក់ពីធនាគារជាតិនៃកម្ពុជារបស់បណ្តាក្រុមហ៊ុនវិនិយោគ
- លិខិតដែលទាក់ទងនឹងកិច្ចការសម្របសម្រួលផ្ទៃក្នុង និងកិច្ចការរដ្ឋបាលរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- លិខិតចាត់តាំងមន្ត្រីចូលរួមសិក្ខាសាលា ឬ ប្រជុំផ្សេងៗ
- លិខិតដែលទាក់ទងនឹងកិច្ចការពាក់ព័ន្ធការគ្រប់គ្រងថវិការបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- លិខិតដែលទាក់ទងនឹងការគ្រប់គ្រងវិមានរដ្ឋាភិបាល និងបរិវេណនៃវិមាន ។

**ប្រការ៣ .-**

អគ្គលេខាធិការគណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជាមានសិទ្ធិចុះហត្ថលេខាលើលិខិត និងឯកសារដូចមានខាងក្រោម :

- លិខិតអនុញ្ញាតដែលពាក់ព័ន្ធនឹងសំណើសុំនាំចូលឧបករណ៍ សម្ភារៈ គ្រឿងចក្រ យានយន្ត និងផលិតផលតេលសិលា ដោយពន្ធ និងអាករជាបន្ទុករបស់រដ្ឋ ក្នុងក្របខ័ណ្ឌគណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា និងលិខិតពន្យាសុពលភាពនៃការអនុញ្ញាតឱ្យនាំចូល
- លិខិតជូនអនុប្រធានទី១ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដើម្បីសុំការណែនាំ ឬការសម្រេចលើបញ្ហាកម្រិតគោលនយោបាយដែលពាក់ព័ន្ធនឹងកិច្ចសហប្រតិបត្តិការ និងភាពជាដៃគូជាមួយដៃគូអភិវឌ្ឍន៍
- លិខិតដែលទាក់ទងនឹងកិច្ចការបច្ចេកទេសនៅក្នុងទំនាក់ទំនងរវាងគណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា និងសមភាគីនានា នៅតាមបណ្តាក្រសួង-ស្ថាប័នផ្សេងៗនៃរាជរដ្ឋាភិបាល
- លិខិតដែលទាក់ទងនឹងកិច្ចការបច្ចេកទេសនៅក្នុងទំនាក់ទំនងរវាងគណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា និងតំណាងអ្នកផ្តល់ជំនួយ

- លិខិតដែលទាក់ទងនឹងកិច្ចការសម្របសម្រួលផ្ទៃក្នុង និងកិច្ចការរបស់គណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍ពម្ពុជា។

**ប្រការ៤ .-**

អគ្គលេខាធិការគណៈកម្មាធិការវិនិយោគកម្ពុជា មានសិទ្ធិចុះហត្ថលេខាលើលិខិត និងឯកសារដូចមានខាងក្រោម :

- លិខិតអញ្ជើញតំណាងប្រធានស្ថាប័នរដ្ឋ និងអភិបាលនៃគណៈអភិបាលរាជធានី-ខេត្ត សម្រាប់ចូលរួមប្រជុំ "ច្រកចេញ-ចូលតែមួយ"
- លិខិតជូនដំណឹង ឬរាល់ការសម្រេចចំពោះសំណើសុំគោលការណ៍វិនិយោគរបស់ក្រុមហ៊ុនឯកជន បន្ទាប់ពីមានការសម្រេចរបស់ប្រធាន ឬអនុប្រធានទី១ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា លើរបាយការណ៍អង្គប្រជុំ "ច្រកចេញ-ចូលតែមួយ"
- លិខិតអនុញ្ញាតដែលពាក់ព័ន្ធនឹងសំណើសុំនាំចូលគ្រឿងចក្រ សម្ភារៈ ឧបករណ៍ វត្ថុធាតុដើម ធាតុចូលដទៃទៀត និងយានយន្ត ដោយពន្ធនាំចូលជាបន្ទុករបស់រដ្ឋ ក្នុងក្របខ័ណ្ឌវិនិយោគឯកជន និងលិខិតពន្យាសុពលភាពនៃការអនុញ្ញាតឱ្យនាំចូល
- លិខិតដែលទាក់ទងនឹងកិច្ចការសម្របសម្រួលផ្ទៃក្នុង និងកិច្ចការរបស់គណៈកម្មាធិការវិនិយោគកម្ពុជា
- លិខិតដែលទាក់ទងនឹងកិច្ចការបច្ចេកទេសនៅក្នុងទំនាក់ទំនងរវាងគណៈកម្មាធិការវិនិយោគកម្ពុជា និងសមភាគីនានា នៅតាមបណ្ដាក្រសួង-ស្ថាប័នផ្សេងៗនៃរាជរដ្ឋាភិបាល
- លិខិតដែលទាក់ទងនឹងកិច្ចការបច្ចេកទេសនៅក្នុងទំនាក់ទំនងរវាងគណៈកម្មាធិការវិនិយោគកម្ពុជា និងមន្ត្រីនៃស្ថានតំណាងបរទេសនានានៅក្នុងព្រះរាជាណាចក្រកម្ពុជា។
- លិខិតដែលទាក់ទងនឹងកិច្ចការបច្ចេកទេសនៅក្នុងទំនាក់ទំនងរវាងគណៈកម្មាធិការវិនិយោគកម្ពុជា និងតំណាងក្រុមហ៊ុនវិនិយោគនានា
- លិខិតស្នើសុំ និងស្នើបន្តទិដ្ឋាការជូនវិនិយោគិន និងបុគ្គលិកបច្ចេកទេសនានា ដែលមកធ្វើការវិនិយោគ និងមកបំពេញការងារនៅក្នុងព្រះរាជាណាចក្រកម្ពុជា ស្របតាមការអនុញ្ញាតនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដើម្បីបញ្ជូនទៅក្រសួងមហាផ្ទៃធ្វើការពិនិត្យ និងសម្រេច។

**ប្រការ៥ .-**

អគ្គលេខាធិការគណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា មានសិទ្ធិចុះហត្ថលេខាលើលិខិត និង ឯកសារដូចមានខាងក្រោម :

- លិខិតអញ្ជើញតំណាងប្រធានស្ថាប័នរដ្ឋ និងអភិបាលនៃគណៈអភិបាលរាជធានី-ខេត្ត សម្រាប់ចូលរួមប្រជុំ "ច្រកចេញ-ចូលតែមួយ"
- លិខិតជូនអនុប្រធានទី១ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សុំពិនិត្យ និងសម្រេចលើគម្រោងវិនិយោគបង្កើតតំបន់សេដ្ឋកិច្ចពិសេស
- លិខិតជូនដំណឹង ឬរាល់ការសម្រេចចំពោះសំណើសុំគោលការណ៍វិនិយោគបង្កើតតំបន់សេដ្ឋកិច្ចពិសេស បន្ទាប់ពីមានការសម្រេចរបស់ប្រធាន ឬអនុប្រធានទី១ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា លើរបាយការណ៍អង្គប្រជុំ "ច្រកចេញ-ចូលតែមួយ"
- លិខិតអនុញ្ញាតដែលពាក់ព័ន្ធនឹងសំណើសុំនាំចូលឧបករណ៍សម្ភារៈបរិក្ខារ សម្ភារៈសាងសង់ ដោយពន្ធនាំចូល និងអាករផ្សេងៗជាបន្ទុករបស់រដ្ឋ សម្រាប់បម្រើឱ្យការសាងសង់ហេដ្ឋារចនាសម្ព័ន្ធក្នុងតំបន់របស់អ្នកអភិវឌ្ឍន៍តំបន់ និងលិខិតពន្យាសុពលភាពនៃការអនុញ្ញាតឱ្យនាំចូល
- លិខិតដែលទាក់ទងនឹងកិច្ចការសម្របសម្រួលផ្ទៃក្នុង និងកិច្ចការរបស់គណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា
- លិខិតដែលទាក់ទងនឹងកិច្ចការបច្ចេកទេសនៅក្នុងទំនាក់ទំនងរវាងគណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា និងសមភាគីនានា នៅតាមបណ្ដាក្រសួង-ស្ថាប័នផ្សេងៗនៃរាជរដ្ឋាភិបាល
- លិខិតដែលទាក់ទងនឹងកិច្ចការបច្ចេកទេសនៅក្នុងទំនាក់ទំនងរវាងគណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា និងមន្ត្រីនៃស្ថានតំណាងបរទេសនានានៅក្នុងព្រះរាជាណាចក្រកម្ពុជា
- លិខិតដែលទាក់ទងនឹងកិច្ចការបច្ចេកទេសនៅក្នុងទំនាក់ទំនងរវាងគណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា និងតំណាងក្រុមហ៊ុនវិនិយោគនានា
- លិខិតស្នើសុំ និងស្នើបន្តទិដ្ឋាការជូនវិនិយោគិន និងបុគ្គលិកបច្ចេកទេសនានា ដែលមកធ្វើការវិនិយោគ និងមកបំពេញការងារនៅក្នុងព្រះរាជាណាចក្រកម្ពុជា ស្របតាមការអនុញ្ញាតនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដើម្បីបញ្ជូនទៅក្រសួងមហាផ្ទៃធ្វើការពិនិត្យ និងសម្រេច។

**ប្រការ៦ .-**

ក្នុងករណីថ្នាក់ដឹកនាំណាម្នាក់អវត្តមាន ការទទួលខុសត្រូវជំនួសត្រូវផ្ទេរជូនថ្នាក់ដឹកនាំបន្តបន្ទាប់ស្របតាមឋានានុក្រម និងស្របតាមភារកិច្ចទទួលខុសត្រូវរៀងៗខ្លួន។

**ប្រការ៧ .-**

បញ្ញត្តិទាំងឡាយណាដែលផ្ទុយពីសេចក្ដីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៨ .-**

ឧបនាយករដ្ឋមន្ត្រីប្រចាំការ និងជាអនុប្រធានទី១ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងពាណិជ្ជកម្ម និងជាអនុប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា អគ្គលេខាធិការគណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា អគ្គលេខាធិការគណៈកម្មាធិការវិនិយោគកម្ពុជា អគ្គលេខាធិការគណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា និងគ្រប់នាយកដ្ឋាន គ្រប់ផ្នែកចំណុះក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ត្រូវអនុវត្តន៍សេចក្ដីសម្រេចនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១៣

**នាយករដ្ឋមន្ត្រី**

**ប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

ចម្លងជូន:
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង-ស្ថាប័នរាជរដ្ឋាភិបាល
- ប្រការ ៨ "ដើម្បីអនុវត្តន៍"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ